# ចរិតលក្ខណៈសំខាន់ៗបំផុត
# របស់អ្នកធ្វើការ
# ដែលមានការលើកទឹកចិត្តខ្ពស់





- ខ្ញុំមកធ្វើការទាន់ពេលវេលា ចាប់ផ្ដើមការងារទៀងពេល និងធ្វើការក្នុងប្រកពាម៉ឹងម៉ាត់ លើកលែងតែនៅពេលសម្រាក។
- ខ្ញុំពិនិត្យនិងកែកំហុសការងារយ៉ាងរហ័សព្រមទាំងជៀសវាងកំហុសទាំងនេះកើតឡើងវិញ។ ខ្ញុំអាចសុំជំនួយនៅពេលដែលខ្ញុំមិនដឹងពីរបៀបក្នុងការកែកំហុសរបស់ខ្ញុំ។
- ខ្ញុំពាក់សម្លៀកបំពាក់ស្អាត និងសមរម្យសម្រាប់ការងាររបស់ខ្ញុំ។ ខ្ញុំងូតទឹករាល់ថ្ងៃ និងប្រើថ្នាំបំបាត់ក្លិន។
- ខ្ញុំធ្វើកិច្ចការបានត្រឹមត្រូវ និងបញ្ចប់វាទាន់ពេល។
- នៅពេលខ្ញុំបញ្ចប់ការងារដែលគេប្រគល់ឲ្យ ខ្ញុំយកការងារដទៃមកធ្វើ។



- ខ្ញុំសហការជាមួយមិត្តរួមការងារ ដើម្បីសម្រេចគោលបំណងរបស់ក្រុមតាមពេលកំណត់។ នៅពេលខ្ញុំបញ្ចប់ការងាររបស់ខ្ញុំ ខ្ញុំជួយធ្វើការរបស់អ្នកដទៃ។
- ខ្ញុំរួសរាយរាក់ទាក់ និងគោរពអ្នកគ្រប់គ្រងរបស់ខ្ញុំ មិត្តរួមការងារ និងអតិថិជនដោយសេចក្ដីគោរព និងភាពគួរសម។ ខ្ញុំចូលចិត្តជួយអតិថិជនគ្រប់គ្នា។
- ខ្ញុំជាអ្នកធ្វើការតាមវិន័យសុវត្ថិភាព និងចេះខ្វល់ខ្វាយពីមិត្តរួមការងារ។
- ខ្ញុំមានមោទនភាពចំពោះការងាររបស់ខ្ញុំ ដូច្នេះហើយខ្ញុំធ្វើវាបានល្អ។ នៅពេលដែលខ្ញុំបញ្ចប់ផ្នែកខ្លះនៃការងាររបស់ខ្ញុំ ខ្ញុំចំណាយពេលបន្តិចដើម្បីឲ្យតម្លៃទៅលើអ្វីដែលខ្ញុំបានធ្វើ។



- ខ្ញុំសម្រាក និងទទួលទានអាហារមានជីវជាតិគ្រប់គ្រាន់ ព្រមទាំងហាត់ប្រាណ លេងកីឡា និងសកម្មភាពសម្រាកលំហែផ្សេងៗ។
- ខ្ញុំមានទំនុកចិត្ត និងជឿជាក់ថាការងាររបស់ខ្ញុំទទួលបានជោគជ័យ។
- ខ្ញុំប្ដេជ្ញាក្នុងចិត្តថានឹងធ្វើការរបស់ខ្ញុំឲ្យបានល្អ មិនថាតែខ្ញុំធ្វើការឲ្យអ្នកដទៃ ឬខ្លួនឯងនោះទេ។
- ខ្ញុំចូលចិត្តរៀនជំនាញថ្មីៗ និងមានទំនួលខុសត្រូវគ្រប់យ៉ាងចំពោះ អ្វីដែលស្ថិតនៅក្នុងរង្វង់ការងាររបស់ខ្ញុំ។



- ខ្ញុំសុំ "ច្បាប់ឈឺ" នៅពេលដែលខ្ញុំឈឺពិតប្រាកដ ហើយខ្ញុំប្រាប់អ្នកគ្រប់គ្រងរបស់ខ្ញុំយ៉ាងលឿនបំផុតតាមដែលអាចធ្វើបាន ដើម្បីឲ្យគាត់រកគេមកបំពេញភារកិច្ចជំនួស។
- ខ្ញុំរាយការណ៍ទៅអ្នកគ្រប់គ្រងរបស់ខ្ញុំយ៉ាងរហ័ស ប្រសិនបើខ្ញុំឃើញបញ្ហាសំខាន់ណាមួយកើតឡើងក្នុងកន្លែងធ្វើការ។
- នៅពេលខ្ញុំបញ្ចប់ការងារដែលគេប្រគល់ឲ្យ ខ្ញុំរកមើលអ្វីផ្សេងទៀតដែលត្រូវការធ្វើបន្ថែម។
- ខ្ញុំស្វែងរកមធ្យោបាយដើម្បីធ្វើឲ្យការងាររបស់ខ្ញុំកាន់តែប្រសើរ និងមានប្រសិទ្ធភាពខ្ពស់។
- ខ្ញុំកត់សម្គាល់ និងគិតអំពីការងាររបស់ខ្ញុំទាំងមូល ព្រមទាំងរបៀបរៀបចំការងារឲ្យកាន់តែប្រសើរ។